**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ: ០០៥ ស.អ.យ.

ថ្ងៃព្រហស្បតិ៍ ៨កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១

# សារាចរណែនាំ
# ស្តីពី
# ការអបអរសាទរខួបលើកទី ១៤ ទិវាអតីតយុទ្ធជនកម្ពុជា ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០០៧ - ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២១

យោងតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៣១ សសរ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការកំណត់ទិវាអតីតយុទ្ធជន ថ្ងៃទី២១ ខែមិថុនា។

ដើម្បីអបអរសាទរខួបលើកទី ១៤ ទិវាអតីតយុទ្ធជនកម្ពុជា ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ នេះឱ្យបានស័ក្តិសមទៅនឹងគុណបំណាច់ដ៏ធំធេងរបស់អតីតយុទ្ធជនចំពោះជាតិមាតុភូមិ និងប្រជាជន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំដូចខាងក្រោម៖

១- មន្ទីរ ស.អ.យ. រាជធានី ខេត្ត ត្រូវសហការជាមួយ ស.អ.ក. រាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្ត ចាត់តាំងពិធីអបអរសាទរខួបលើកទី១៤ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា តាមរូបភាព និងខ្លឹមសារដូចតទៅ៖

- ផ្សព្វផ្សាយសារាចរ ស្តីពីការអបអរសាទរខួបលើកទី១៤ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា របស់រាជរដ្ឋាភិបាលកម្ពុជា
- ផ្សព្វផ្សាយសារលិខិត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

២- ប្រធានមន្ទីរ ស.អ.យ. រាជធានី ខេត្ត សហការជាមួយប្រធានគណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ត្រូវរៀបចំគណៈកម្មការចាត់តាំងខួបលើកទី១៤ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា ដោយ៖

- ត្រូវកោះប្រជុំស.អ.ក. គ្រប់ ក្រុង ស្រុក ខណ្ឌ ដើម្បីផ្សព្វផ្សាយផែនការឱ្យទាន់ពេលវេលា
- ត្រូវចាត់តាំងពិធីសំណេះសំណាលជាមួយបងប្អូនអតីតយុទ្ធជន ក្នុងខួបលើកទី១៤ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា និងការបង្កើត ស.អ.ក. រាជធានី ខេត្ត ដោយប្រកាន់ខ្ជាប់នូវវិធានការ ៣កុំ ៣ការពារ របស់រាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។
- ត្រូវប្រើប្រាស់ថវិកាមន្ទីរ ស.អ.យ. រាជធានី ខេត្ត និងសុំសហការឧបត្ថម្ភបន្ថែមពី ស.អ.ក. រាជធានី ខេត្ត ឬសប្បុរសជននានាតាមលទ្ធភាព



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៧២៦ ០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh Cambodia. Fax/Phone: (855) 23 726 086

- ត្រូវផ្ញើរបាយការណ៍ស្តីពីពិធីសំណេះសំណាល ខួបលើកទី១៤ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា ឆ្នាំ២០២១ មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (នាយកដ្ឋានអតីតយុទ្ធជន) ឱ្យបានមុនបំណាច់ខែមិថុនា ឆ្នាំ២០២១។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរ ស.អ.យ. រាជធានី ខេត្ត ត្រូវសហការជាមួយ ស.អ.ក.ចាត់តាំងអនុវត្ត ឱ្យមានប្រសិទ្ធភាព។

រដ្ឋមន្ត្រី

វង សូត

**ចម្លងជូន ៖**

- ខុទ្ទកាល័យសម្តេចអគ្គសេនាមហាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ
- ខុទ្ទកាល័យលោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី
- គណៈអចិន្ត្រៃយ៍ ស.អ.ក.
- សាលារាជធានី ខេត្ត
- មន្ទីរ ស.អ.យ. រាជធានី ខេត្ត
- គណៈកម្មាធិការ ស.អ.ក. រាជធានីខេត្ត
- ឯកសារ-កាលប្បវត្តិ